# ហេតុអ្វីជំរឿនមានសារៈសំខាន់សំរាប់ មនុស្សចាស់អាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍

ជារៀងរាល់10ឆ្នាំម្តង រដ្ឋាភិបាលសហរដ្ឋអាមេរិកតម្រូវឱ្យមានការរាប់ចំនួន **មនុស្សគ្រប់រូប** ដែលរស់នៅក្នុងសហរដ្ឋអាមេរិកតាមរយៈការស្ទង់មតិមួយដែលគេហៅថា “ជំរឿនប្រជាជន”។ ជំរឿនប្រជាជនឆ្នាំក្រោយនឹងចាប់ផ្តើមនៅខែមីនាឆ្នាំ2020 ហើយវានឹងកំណត់ថាតើថវិការដ្ឋាភិបាលសហព័ន្ធចំនួន 800 ពាន់លានដុល្លារនឹងត្រូវបែងចែកទៅដល់សហគមន៍ទូទាំងប្រទេសយ៉ាងដូចម្តេច។

## តើលោកអ្នកដឹងទេ?

ប្រជាជនអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍ទាំងអស់នៅក្នុងសហរដ្ឋអាមេរិកស្ទើរតែ14% មានអាយុ55ឆ្នាំឡើងទៅ ហើយមនុស្សចាស់នៅក្នុងសហគមន៍ជនជាតិវៀតណាមមានចំនួនច្រើនជាងគេរហូតដល់ទៅ 19.4% រីឯចំនែកមនុស្សចាស់នៅក្នុងសហគមន៍ជនជាតិម៉ុងមានចំនួនតិចជាងគេត្រឹមតែ7%ប៉ុណ្ណោះ។[1]




បើទោះជាប្រជាជនអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍ ជាទូទៅមានវ័យក្មេងជាងបើប្រៀបធៀបទៅនឹង ចំនួនប្រជាជនអាមេរិកជាមធ្យម មនុស្សចាស់អាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍ ជួបប្រទះនូវឧបសគ្គ ជាច្រើនដែលធ្វើអោយមានការពិបាកក្នុងការរាប់ចំនួនពួកគាត់ ដែលឧបសគ្គនោះមានដូចជាៈ

- ✓ មិនសូវចេះភាសាអង់គ្លេស
- ✓ មិនសូវចេះពីបច្ចេកវិទ្យា
- ✓ មានប្រាក់ចំណូលទាប ឬរស់នៅក្នុងភាពក្រីក្រ
- ✓ មិនសូវរៀនបានខ្ពង់ខ្ពស់

[1] American Community Survey, 2015 5-year estimates

- ✓ រស់នៅក្នុងគ្រួសារដែលមានចំនួនសមាជិកច្រើន

### សំណួរដែលមានគេសួរច្រើន

## ហេតុអ្វីបានជាមនុស្សចាស់គួរយកចិត្តទុកដាក់ចំពោះការរាប់បញ្ចូលក្នុងជំរឿន?

ការរាប់ចំនួនប្រជាជនតាមរយៈជំរឿនគឺជួយកំណត់
ថាតើធនធានឬថវិកាប៉ុន្មាននឹងត្រូវបែងចែកទៅដល់
កម្មវិធីជួយជនក្រីក្រនិងមនុស្សចាស់ជរា ដែលមានដូចជាកម្មវិធីអប់រំសំរាប់មនុស្សពេញវ័យ
សេវាកម្មសុខភាពនិងអប់រំសំរាប់ជនពិការ សេវាកម្មសំរាប់អ្នកមិនសូវចេះភាសាអង់គ្លេស
កម្មវិធីជំនួយរបស់រដ្ឋដែលមានដូចជា កម្មវិធីជួយផ្នែកម្ហូបអាហារដែលហៅថាហ្វូតស្តែម
និងកម្មវិធីធានារ៉ាប់រងសុខភាព មេឌីឃេត(Medicaid) មេឌីឃែរ (Medicare )
កម្មវិធីថែរក្សាសុខភាព មន្ទីរពេទ្យ
កម្មវិធីផ្តល់លំនៅដ្ឋានដែលមានតំលៃសមរម្យតាមប័ណ្ណជំនួយផ្នែកទី8 (Section 8)
កម្មវិធីជួយរកការងារដល់មនុស្សចាស់ និងកម្មវិធីជាច្រើនទៀត ។
នៅពេលដែលលោកអ្នកបានបំពេញជំរឿន លោកអ្នកបានចូលរួមជួយធានាអោយបានថា
លោកអ្នកនិងគ្រួសាររបស់លោកអ្នក ទទួលបានចំណែកស្មើគ្នា ពីថវិការដ្ឋចំនួន 800
ពាន់លានដុល្លារសំរាប់ជួយដល់កម្មវិធីនិងសេវាកម្មនានាដែលមានសារៈសំខាន់សំរាប់សុខភាពនិងសុខមាលភាពរបស់លោកអ្នក។




## តើខ្ញុំត្រូវចូលរួមក្នុងជំរឿនដោយរបៀបណាដែរ បើខ្ញុំមិនមានកុំព្យូទ័រសំរាប់ប្រើ?

លោកអ្នកនៅតែអាចចូលរួមក្នុងជំរឿនបានតាមរយៈទូរស័ព្ទ ឬបំពេញក្រដាសជំរឿនដោយដៃ។
បើទោះជាគ្រប់ក្រុមគ្រួសារទាំងអស់ប្រហែលជាមិនបានទទួលក្រដាសជំរឿនដែលផ្ញើតាមប៉ុស្តិ៍សំបុត្រលើកដំបូង ក្រុម គ្រួសារទាំងអស់ដែលមិនបានបំពេញក្រដាសជំរឿនអោយបានត្រឹមថ្ងៃទី16 ដល់18 ខែមេសា អាចនឹងទទួលបានក្រដាសជំរឿនយកមកបំពេញដោយដៃតាមរយៈប៉ុស្តិ៍សំបុត្រម្តងទៀត។
លោកអ្នកក៏អាចទៅសាកសួរជាមួយនិងអង្គការឬសមាគមន៍នៅក្នុងមូលដ្ឋានរបស់លោកអ្នក
មជ្ឈមណ្ឌលសហគមន៍ ឬ បណ្ណាល័យ ដើម្បីសាកសួរថាតើពួកគាត់អាចជួយអ្វីបាន
ឬអាចអោយប្រើកុំព្យូទ័របានដែរឬទេ។

## តើមានជំនួយអ្វីខ្លះសំរាប់អ្នកដែលមិនចេះអាន សរសេរ ឬនិយាយភាសាអង់គ្លេសបានល្អ?

ប័ណ្ណជំរឿនដែលបំពេញដោយខ្លួនឯងតាមប្រព័ន្ធអ៊ិនធឺណែត និងប្រព័ន្ធទូរស័ព្ទសំរាប់ជួយក្នុងការបំពេញជំរឿន មានផ្តល់ជូនជា**12** ភាសាខុសៗគ្នា ដែលរួមមានទាំងភាសាវៀតណាមផងដែរ។
ការិយាល័យជំរឿនក៏មានផ្តល់ជាសទ្ទានុក្រមជាភាសាផ្សេងៗ  កាតសំរាប់សំគាល់ភាសានានា និងសៀវភៅមគ្គុទេសភាសាដែលមានភាសាចំនួន**59**ខុសៗគ្នា ដែលរួមមានទាំង ភាសាម៉ុង ភាសាខ្មែរ ភាសាឡាវ និងភាសាវៀតណាម។

## តើមានអ្វីខ្លះជាជំនួយដល់អ្នកដែលមិនចេះអានអក្សរ?

លោកអ្នកនៅតែអាចចូលរួមក្នុងជំរឿនបានតាមរយៈទូរស័ព្ទ។

## តើមានអ្វីខ្លះជាជំនួយដល់អ្នកដែលពិការរាងកាយនិងពិបាកក្នុងការបំពេញជំរឿន?

លោកអ្នកនៅតែអាចចូលរួមក្នុងជំរឿនបានតាមរយៈទូរស័ព្ទ ឬតាមប្រព័ន្ធអ៊ិនធឺរណែតដោយមានប្រព័ន្ធបច្ចេកវិទ្យាសំរាប់ជួយលោកអ្នក។ លោកអ្នកក៏អាចសុំអោយសមាជិកគ្រួសារឬមិត្តភក្តិរបស់លោកអ្នកណាម្នាក់ជួយបំពេញក្រដាសជំរឿនអោយបានដែរ។

## តើខ្ញុំអាចអោយអ្នកផ្សេងណាម្នាក់ឆ្លើយសំណួរជំរឿនជំនួសខ្ញុំបានទេ?

មិនបានទេ។ បើទោះជាលោកអ្នកអាចសុំអោយអ្នកណាម្នាក់ជួយណែនាំពីការបំពេញក្រដាសជំរឿន និងជួយបកប្រែអោយ លោកអ្នកមិនអាចអោយជនណាម្នាក់ បំពេញចំលើយជំរឿនជំនួសលោកអ្នកបានទេ។

## **សូមចូលរួមអនុវត្តសកម្មភាពខាងក្រោម៖**

ត្រូវដឹងថា ចូលរួមក្នុងការរាប់ចំនួនប្រជាជនគឺមានឥទ្ធិពល! សូមចុះឈ្មោះធ្វើជាទូតជំរឿនឆ្នាំ2020 និងជួយធានាអោយបានថាបងប្អូនជនជាតិអាមេរិកដើមកំណើតអាស៊ីអាគ្នេយ៍យើងទាំងអស់ត្រូវបានគេស្គាល់និងដឹងលឺ។ សូមស្វែងយល់បន្ថែមតាមរយៈ៖ bit.ly/SEARACCensusPledge ។

## តើលោកអ្នកអាចធ្វើអ្វីខ្លះដើម្បីធានាអោយបានថាលោកអ្នកត្រូវបានគេរាប់បញ្ចូលក្នុងជំរឿន?

1. បំពេញក្រដាសជំរឿនរបស់លោកអ្នក។ ហើយជួយប្រាប់ដល់មិត្តភក្តិនិងក្រុមគ្រួសាររបស់លោកអ្នកអំពីជំរឿនប្រជាជន និងជួយពន្យល់ពួកគាត់អំពីសារៈសំខាន់នៃការចូលរួមក្នុងជំរឿន។
2. ឆែកមើលឯកសារព័ត៍មានខាងក្រោមនេះ resource(s) page  ដើម្បីអោយដឹងថា នៅពេលណាដែលក្រដាសជំរឿននឹងធ្លាក់មក របៀបបំពេញក្រដាសជំរឿន មានផ្តល់ជូនជាភាសាអ្វីខ្លះ ក៏ដូចជាព័ត៍មានជាច្រើនទៀតផងដែរ។
3. ដាក់ពាក្យចូលធ្វើការឱ្យការិយាល័យជំរឿន ជាមន្ត្រីចុះធ្វើជំរឿន ដែលជាអ្នកចុះទៅដល់ផ្ទះរបស់ប្រជាជនដើម្បីរាប់ពួកគាត់ប្រសិនបើពួកគាត់មិនបានបំពេញជំរឿន។ សូមស្វែងរកព័ត៍មានបន្ថែមនៅទីនេះ here!

សូមថ្លែងអំណរគុណដល់ដៃគូសហការរបស់យើង ដែលមានដូចជាអង្គការ Boat People SOS-Houston, The Cambodian Family of Santa Ana, Freedom Inc., the Fresno Center, និងអង្គការ Iu-Mien Community Services ដែលបានជួយបកប្រែឯកសារទាំងនេះ។
ឯកសារផ្តល់ជូនព័ត៍មានពិតទាំងអស់នេះអាចទាញយកបានជាទំរង់ឯកសារWord និងអាចកែតំរូវទៅតាមតំរូវការរបស់សហគមន៍ផ្សេងៗ។ សម្រាប់សំណួរបន្ថែម សូមទាក់ទងតាមរយៈអ៊ីមែលsearac@searac.org